ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាល

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងរដ្ឋប្បវេណីលេខៈ ៣៩៦

ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១

សាលក្រមលេខៈ ០៩ (ប)

ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១

ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

-វាងដើមឈ្មោះ [redacted] កន្និដ្ឋា ភេទស្រី កើតថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩០ ជនជាតិខ្មែរ មុខរបររដ្ឋករទឹក ទីលំនៅបច្ចុប្បន្ន [redacted] ប្តីឈ្មោះ [redacted] លីហ្សួត មានកូន ០២ នាក់។

-អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted] មានការិយាល័យតាំងនៅអគារ [redacted] ។

-ចុងចម្លើយឈ្មោះ [redacted] លីហ្សួត ភេទប្រុស កើតថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៨២ ជនជាតិខ្មែរ មុខរបរ ធ្វើការក្រុមហ៊ុន ទីលំនៅបច្ចុប្បន្ន [redacted] ប្រពន្ធឈ្មោះ [redacted] កន្និដ្ឋា មានកូន ០២ នាក់ ។

-អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted] ,លោកមេធាវី [redacted] និងលោកមេធាវី [redacted] មានអាស័យដ្ឋាន [redacted] ។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

*១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖*

១/ឲ្យដើមចោទឈ្មោះ [redacted] កន្និដ្ឋា លែងលះពីចុងចម្លើយឈ្មោះ [redacted] លីហ្សួត ចាប់ពីពេលនេះតទៅ ។

២/ឲ្យដើមចោទឈ្មោះ [redacted] កន្និដ្ឋាជាម្តាយ ជាអ្នកមានអំណាចមេបាក្នុងការចិញ្ចឹមកូន គ្រប់គ្រងបីបាច់ និងថែរក្សាលើកូនស្រីចំនួន០២ នាក់ ដែលកូនស្រីទី១/ឈ្មោះ [redacted] កែវស្សូរីកា កើតថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ និងកូនស្រីទី២/ឈ្មោះ [redacted] កែវរតនធីតា កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១។

៣/បង្គាប់ឲ្យចុងចម្លើយប្រគល់កូនឈ្មោះ [redacted] កែវស្សូរីកា ទៅឲ្យដើមចោទដែលជាអ្នកមានអំណាចមេបាលើកូន។

៤/ឲ្យចុងចម្លើយបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាពរបស់ខ្លួន។

៥/សាលក្រមនេះមានអានុភាពអនុវត្តបណ្តោះអាសន្ន។



Scanned with CamScanner

២.ការអះអាងរបស់ភាគី

ក-ដើមចោទឈ្មោះ [redacted] កន្និដ្ឋា ថ្លែងការណ៍ថា៖ ខ្លួនប្រកាន់ជំហរលែងលះពីចុងចម្លើយឈ្មោះ [redacted] លីហ្វួត ដដែល ដោយមូលហេតុរស់នៅមិនចុះសំរុងគ្នា។ ខ្លួនបានរៀបការនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៤ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ព្រែកប្ញស្សី។ខ្លួនបានបែកលំនៅដ្ឋានគ្នារយៈពេលបីខែមកហើយ និងការរស់នៅជាមួយគ្នាមានកូន២នាក់ទី១/ឈ្មោះ [redacted] កែវសូរីកា ភេទស្រី កើតថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ និងកូនទី២/ឈ្មោះ [redacted] កែវរតនធីតា ភេទស្រី កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ គឺកូនទី១នៅខាងប្តីចិញ្ចឹម នៅពេលនេះខ្លួនប្រគល់ឱ្យទៅប្តីគ្រប់គ្រងចិញ្ចឹមថែរក្សា រីឯកូនទី២ នៅខាងខ្លួនចិញ្ចឹម ខ្លួនសុំគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា និងសោហ៊ុយចិញ្ចឹមកូនមិនទាមទារទេ ដោយខ្លួនធ្វើការនៅរង្គាករទឹកបានប្រាក់ខែ ក្នុង១ខែ ចំនួន ៥០០ដុល្លា អាចចិញ្ចឹមកូនបាន និងសុំសាលក្រមអនុវត្តបណ្តោះអាសន្ន។

ខ.ចុងចម្លើយឈ្មោះ [redacted] លីហ្វួត ថ្លែងការណ៍ថា៖ ខ្លួនឯកភាពលែងលះតាមការស្នើសុំរបស់ដើមចោទ ពេលរៀបអាពាហ៍ពិអាហ៍រួច គឺរស់នៅជាមួយគ្នាធម្មតាទេ។ នៅឆ្នាំ២០១៨ មានការរកាំងរកូសគ្នាពីការទិញដីនៅផ្លូវលេខ៦០ ជាហេតុរស់នៅមិនចុះសំរុងគ្នា។ ខ្លួនរៀបការនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៤ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ព្រែកប្ញស្សី។ ខ្លួនបានបែកលំនៅដ្ឋានគ្នារយៈពេលបីខែមកហើយ និងការរស់នៅជាមួយគ្នាមានកូន២នាក់ទី១/ឈ្មោះ [redacted] កែវសូរីកា ភេទស្រី កើតថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ និងកូនទី២/ឈ្មោះ [redacted] កែវរតនធីតា ភេទស្រី កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ គឺកូនទី១នៅខាងខ្លួនចិញ្ចឹម ខ្លួនសុំគ្រប់គ្រងចិញ្ចឹមកូននេះ តែកូនទី២ នៅខាងប្រពន្ធ ខ្លួនប្រគល់ឱ្យប្រពន្ធចិញ្ចឹមថែរក្សា ,ចំពោះសោហ៊ុយចិញ្ចឹមកូនទី២ ខ្លួនសុខចិត្តចិញ្ចឹមកូនតាមលទ្ធភាពរបស់ខ្លួន ដោយខ្លួនធ្វើការនៅក្រុមហ៊ុនបានប្រាក់ខែ ក្នុង០១ខែ ចំនួន ៣០០០ដុល្លា ដែរ និងសុំសិទ្ធិទៅសួរសុខទុក្ខកូននៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ។

-សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] កន្និដ្ឋា៖ គូភាគីឯកភាពគ្នាលែងលះ ,ឯកភាពគ្នាបែងចែកកូនម្នាក់មួយ ដូច្នេះស្នើសុំតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

-សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] លីហ្វួត៖ គូភាគីឯកភាពគ្នាលែងលះ ,ឯកភាពគ្នាបែងចែកកូនម្នាក់មួយ ដូច្នេះស្នើសុំតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី យោងតាមមាត្រា ៩៧៩ និងមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។

៣.ការពន្យល់ត្រួសៗអំពីរឿងក្តី

ដើមចោទឈ្មោះ [redacted] កន្និដ្ឋា និងចុងចម្លើយឈ្មោះ [redacted] លីហ្វួត បានរៀបការជាប្តីប្រពន្ធ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៤ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ និងបានបង្កើតកូនចំនួនពីរនាក់ កូនទី១/ឈ្មោះ [redacted] កែវសូរីកា ភេទស្រី កើតថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ , កូនទី២/ឈ្មោះ [redacted] កែវរតនធីតា ភេទស្រី កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១។ ដើមចោទឈ្មោះ [redacted] កន្និដ្ឋា និងចុងចម្លើយឈ្មោះ [redacted] លីហ្វួត ចាប់ពីថ្ងៃដែលរស់នៅ

ជាប្តីប្រពន្ធរហូតមកដល់បច្ចុប្បន្ន ហើយបានខិតខំធ្វើការរកស៊ីចិញ្ចឹមគ្រួសាររហូតមក។ នៅក្នុងអំឡុងឆ្នាំ២០១៨ មានការរកាំងរកូសគ្នារឿងទិញដីនៅផ្លូវលេខ៦០ ជាមូលហេតុរស់នៅមិនចុះសំរុងគ្នា និងបានបែកលំនៅដ្ឋានរយៈពេលបីខែមកហើយ។

៤.ចំណុចវិវាទ: គ្មាន ដោយគូភាគីឯកភាពគ្នាលែងលះ ,ឯកភាពគ្នាបែងចែកកូនម្នាក់មួយដោយដើមចោទឈ្មោះ [redacted] កន្និដ្ឋា គ្រប់គ្រងកូនទី២ ឈ្មោះ [redacted] កែវរតនធីតា ភេទស្រី កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ រីឯចុងចម្លើយឈ្មោះ [redacted] លីហ្វូត គ្រប់គ្រងកូនទី១ ឈ្មោះ [redacted] កែវស្វរីកា ភេទស្រី កើតថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥។

## សំអាងហេតុ

១-ដើមចោទឈ្មោះ [redacted] កន្និដ្ឋា និងចុងចម្លើយឈ្មោះ [redacted] លីហ្វូត ពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្តីប្រពន្ធនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមលិខិតលេខ ៥០ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ នៅមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ព្រែកឫស្សី។

២-គូភាគីអះអាងនៅដំណាក់កាលទាញហេតុដោយផ្ទាល់មាត់ថា ការរស់នៅជាមួយគ្នាមិនចុះសម្រុងគ្នាអស់មនោសញ្ចេតនាគ្នាជាប្តីប្រពន្ធ ហើយគូភាគីបានឯកភាពលែងលះគ្នាជាមួយគ្នាដោយស្មគ្រ័ចិត្ត ហេតុនេះតុលាការសម្រេច តាមការព្រមព្រៀងរបស់គូភាគី យោងតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

៣-ការរស់នៅជាមួយគ្នាកន្លងមក គូភាគីមានកូនចំនួនពីរនាក់ កូនទី១/ឈ្មោះ [redacted] កែវស្វរីកា ភេទស្រី កើតថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ , កូនទី២/ឈ្មោះ [redacted] កែវរតនធីតា ភេទស្រី កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ ហើយគូភាគីឯកភាពគ្នាបែងចែកសិទ្ធិគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាកូនម្នាក់មួយ ដោយកូនទី១ចុងចម្លើយឈ្មោះ [redacted] លីហ្វូត សុំសិទ្ធិគ្រប់គ្រងចិញ្ចឹម រីឯកូនទី២ឈ្មោះ [redacted] កែវរតនធីតា ដើមចោទឈ្មោះ [redacted] កន្និដ្ឋា សុំសិទ្ធិជាអ្នកគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា ដូច្នេះតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី យោងមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។ គូភាគីត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងឱ្យគ្នាទៅវិញទៅមកក្នុងការសួរសុខទុក្ខកូន ហើយភាគីចុងចម្លើយបានបញ្ជាក់ថា ទោះបីកូនចែកគ្នាម្នាក់មួយក៏ដោយក៏ខ្លួនជួយផ្តល់សោហ៊ុយចិញ្ចឹមកូនទី២ ដែរស្របតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី។

៤-ដើមចោទឈ្មោះ [redacted] កន្និដ្ឋា សុំឱ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្ន ការស្នើសុំនេះ គប្បីច្រានចោល ដោយហេតុថា ការប្រកាសអនុវត្តជាបណ្តោះអាសន្នចំពោះសាលក្រម តុលាការអាចពិនិត្យសម្រេចបានតែអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិតែប៉ុណ្ណោះ ដែលមានចែងតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៥-ដើមចោទឈ្មោះ [redacted] កន្និដ្ឋា ត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តី យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១/-ឱ្យដើមចោទឈ្មោះ [redacted] កន្និដ្ឋា និងចុងចម្លើយឈ្មោះ [redacted] លីហ្វូត លែងលះគ្នាតាមការព្រមព្រៀងរបស់គូភាគី យោងតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។



Scanned with CamScanner

២/-ប្រគល់កូនទី១/ឈ្មោះ [redacted] កែវសូរីកា ភេទស្រី កើតថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ឱ្យទៅចុងចម្លើយឈ្មោះ [redacted] លីហួត គ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាតាមការព្រមព្រៀងរបស់គូភាគី យោងតាមមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

៣/-ប្រគល់កូនទី២/ឈ្មោះ [redacted] កែវរតនធីតា ភេទស្រី កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ ឱ្យទៅដើមចោទឈ្មោះ [redacted] កន្និដ្ឋា គ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាតាមការព្រមព្រៀងរបស់គូភាគី យោងតាមមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

៤/-ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ [redacted] កន្និដ្ឋា ត្រង់ចំណុចសុំអនុវត្តជាបណ្ដោះអាសន្ន។

៥/-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ ចំពោះមុខគូភាគី រក្សាសិទ្ធិប្ដឹងឧទ្ធរណ៍រយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃចន្ទ ១៤រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខេត្តកណ្ដាល ,ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

(បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម)

កណ្ដាល, ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]